*សំណៅដែលបានពិនិត្យផ្ទៀងផ្ទាត់រួច*

# សម័យប្រជុំលើកទី៣០ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

# សេចក្តីផ្តើមនៃរបាយការណ៍ប្រទេស របស់អគ្គលេខាធិការ

# និងឧត្តមស្នងការ ក្នុងរបៀបវារៈត្រង់ចំណុច ២ និងចំណុច ១០

## ភាគទី១

ថ្លែងដោយ លោកស្រី ហ្វ្លាវា ផាន់សៀរី

ឧត្តមស្នងការរងអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

ទីក្រុងហ្សឺណែវ, ៣០ កញ្ញា ២០១៥

សាល XX, វិមានអង្គការសហប្រជាជាតិ

លោកប្រធាន សមាជិក សមាជិកាទាំងអស់នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ជាទីរាប់អាន,

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងឡាយ ជាទីមេត្រី,

នៅរសៀលថ្ងៃនេះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ នឹងមាននៅចំពោះមុខ នូវរបាយការណ៍ចំនួនបួនរបស់អគ្គលេខាធិការ និងឧត្តមស្នងការ ដែលបានដាក់ស្នើក្នុងរបៀប វារៈត្រង់ចំណុច២ និងចំណុច១០ បូករួមទាំងរបាយការណ៍ផ្ទាល់មាត់មួយ និងរបាយការណ៍បច្ចុប្បន្នភាពមួយ ទាក់ទងនឹងប្រទេសមួយចំនួនដូចជា៖ បូកូហារ៉ាម (Boko Haram), ស៊ូដង់ខាងត្បូង (South Sudan), មីយ៉ាន់ម៉ា (Myanmar), យ៉េម៉ែន (Yemen), កម្ពុជា (Cambodia) និងអ៊ីរ៉ាក់ (Iraq)។ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នឹងមានផងដែរ នៅចំពោះមុខ នូវរបាយការណ៍សង្ខេបមួយ ស្តីពីលទ្ធផលនៃកិច្ចពិភាក្សារបស់ក្រុម ដែលបានធ្វើឡើងនាសម័យប្រជុំលើកទីម្ភៃប្រាំបី លើបញ្ហាស្តីពីគោលនយោបាយជាតិ និងសិទ្ធិមនុស្ស (A/HRC/30/28)។

ឧបការីអគ្គលេខាធិការ (ASG) នឹងធ្វើការណែនាំអំពីរបាយការណ៍ទាក់ទងនឹងប្រទេស ស៊ូដង់ខាងត្បូង (South Sudan),  បូកូហារ៉ាម (Boko Haram) និងអ៊ីរ៉ាក់ (Iraq) ចំណែកខ្ញុំ នឹងធ្វើការណែនាំអំពីរបាយការណ៍ទាក់ទងនឹងប្រទេសមីយ៉ាន់ម៉ា (Myanmar), យ៉េម៉ែន (Yemen) និងកម្ពុជា (Cambodia)។

ឥឡូវនេះ ចូលដល់របាយការណ៍ស្ដីពីតួនាទី និងសមិទ្ធិផលរបស់ការិយាល័យ OHCHR ក្នុងការជួយប្រទេសកម្ពុជា ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស (A/HRC/30/30)។ របាយការណ៍នេះរៀបរាប់អំពីសកម្មភាពរបស់យើងនៅកម្ពុជា ចន្លោះពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ ក្នុងការជួយរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីពង្រឹងនីតិរដ្ឋ កំណែទម្រង់ពន្ធនាគារ ការពារសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ច និងសេរីភាពជាមូលដ្ឋាន។

រយៈពេលធ្វើរបាយការណ៍នេះ យើងបានឃើញមានកិច្ចព្រមព្រៀងផ្នែកនយោបាយ ដើម្បីបញ្ចប់ភាពជាប់គាំងក្រោយការបោះឆ្នោត រវាងរដ្ឋាភិបាល និងគណបក្សប្រឆាំង។ ទោះជាមានកិច្ចព្រមព្រៀងនេះក៏ដោយ នៅពេលភាពតានតឹងផ្នែកនយោបាយបានធូរស្បើយ គោលជំហររបស់រដ្ឋាភិបាលចំពោះសេរីភាពនៃការសម្ដែងមតិ សេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី **កាន់តែមានការរឹតត្បិតខ្លាំងឡើងៗ។**

ក្នុងបរិបទនេះ យើងបានបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរ សង្គមស៊ីវិល សហគមន៍ និងបុគ្គលនានា ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងសិទ្ធិមនុស្សដែលបន្តកើតមាន និងកំពុងកើតមាន។ យើងបានស្វែងរកវិធានការដំណោះស្រាយពីអ្នកអនុវត្តភារកិច្ច បានតាមឃ្លាំមើលសវនាការ និងការប្រព្រឹត្តិទៅលើអ្នកជាប់ឃុំ និងបានតស៊ូមតិឲ្យមានការបង្កើត ឬការពង្រឹងយន្តការ និងស្ថាប័នជាតិ ដើម្បីការពារសិទ្ធិមនុស្ស។

យើងក៏បានតស៊ូមតិផងដែរឲ្យមានការបង្ការនូវការបញ្ជូនចេញនូវជន**ស្វែងរកសិទ្ធិជ្រកកោន**ត្រឡប់ទៅវិញ។ សេចក្ដីប្រកាសគួរឲ្យព្រួយបារម្ភរបស់រដ្ឋាភិបាលដែលថាខ្លួនគ្រោងនឹងបញ្ជូនខ្លួនជនស្វែងរកសិទ្ធិជ្រកកោនជាង ២០០ នាក់ នៅសប្ដាហ៍ខាងមុខ ដោយមិនធ្វើតាមនីតិវិធីត្រឹមត្រូវ គឺជាកង្វល់យ៉ាងខ្លាំង។ ខ្ញុំសូមចូលរួមគាំទ្រមតិយោបល់ជាច្រើនដែលអំពាវនាវដល់រដ្ឋាភិបាលឲ្យគោរពតាមកាតព្វកិច្ចរបស់ខ្លួនស្របតាមអនុសញ្ញាជនភៀសខ្លួន និងអនុសញ្ញាប្រឆាំងទារុណកម្ម ដោយត្រូវយកចិត្តទុកពិចារណាលើករណីមួយៗរបស់ពួកគេ ដែលនេះជាសិទ្ធិរបស់ជនស្វែងរកសិទ្ធិជ្រកកោនទាំងអស់។

ប្រទេសកម្ពុជា **បានអនុវត្តបន្តនូវកំណែទម្រង់គួរឲ្យស្ងើចសរសើរលើរដ្ឋបាលតុលាការ**ដោយមានការជួយជ្រោមជ្រែងពីយើង។ ប្រការនេះបាននាំឲ្យយើងសម្រេចបានលទ្ធផលគួរឲ្យកត់សម្គាល់ រាប់ទាំងការកាត់បន្ថយបានយ៉ាងច្រើននូវសំណុំរឿងជាប់ឧទ្ធរណ៍ ដែលបានពន្យាពេលយូរហួសហេតុផង។ ទោះជាយ៉ាងនេះក៏ដោយ កង្វល់ដ៏ខ្លាំងនោះគឺឯករាជ្យភាព និងអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ។ ការិយាល័យរបស់យើងប្រចាំនៅកម្ពុជានឹងបន្តកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួងយុត្តិធម៌ និងសមាជិកនានានៃប្រព័ន្ធយុត្តិធម៌ ដើម្បីធ្វើឲ្យប្រសើរលើផ្នែកសំខាន់ៗបីៈ ការកែលំអប្រសិទ្ធភាព ការពង្រឹងឯករាជ្យភាព និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ។

យើងក៏បានបន្តកសាងសមត្ថភាពរបស់សមភាគីជាតិដទៃទៀត **អំពីច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី** និងការប្រើកម្លាំង បន្តកសាងសមត្ថភាពរបស់មន្ត្រីពន្ធនាគារ **អំពីវិធីសាស្ត្រគ្រប់គ្រងពន្ធនាគារដោយផ្តោតលើសិទ្ធិមនុស្ស** និងបន្តកសាងសមត្ថភាពរបស់តួអង្គមកពីខាងរដ្ឋាភិបាល និងខាងវិស័យឯកជន អំពី**ធុរកិច្ច និងសិទ្ធិមនុស្ស**។

ចាប់តាំងពីការបញ្ចប់របាយការណ៍នេះ ការវិវត្តន៍ដ៏គួរឲ្យព្រួយបារម្ភយ៉ាងខ្លាំងបានបន្តកើតមានឡើង រាប់ទាំង ការប្រកាសឲ្យប្រើ **ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល** កាលពីខែសីហា ដែលបង្កើតតម្រូវការថ្មី ដែលបង្កឲ្យមានបញ្ហាដល់អង្គការសង្គមស៊ីវិល និងអនុញ្ញាតឲ្យមានការបដិសេធពីការចុះបញ្ជីដោយមិនមានការពន្យល់ណាមួយឡើយ។ ហេតុនេះហើយ មានហេតុផលសមស្របក្នុងការពិចារណាថា ច្បាប់នេះមិនទាន់ដល់កម្រិតបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិជាធរមាននៅឡើយ ហើយច្បាប់នេះគួរតែត្រូវបានធ្វើវិសោធនកម្មឲ្យបានឆាប់។

ការឃាយីតាមផ្លូវតុលាការដល់គណបក្សដែលមានសំឡេងភាគតិច កាន់តែមានភាពខ្លាំងក្លាឡើង ដោយមានសមាជិក និងអ្នកគាំទ្រចំនួន១១រូប នាពេលថ្មីៗនេះ

**ត្រូវបានកាត់ទោសពីបទ** "កុបកម្ម" និងមានការចោទប្រកាន់ចំនួនបីករណីបន្ថែមទៀត។ ក្នុងដំណើរឆ្ពោះទៅរកការបោះឆ្នោតឃុំ-សង្កាត់ ក្នុងឆ្នាំ២០១៧ ប្រការសំខាន់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីសម្រួល និងការពារដល់ការអនុវត្តសេរីភាពជាមូលដ្ឋាន។

នៅក្នុងបរិបទនេះ ខ្ញុំសូមបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តរបស់យើងក្នុងការជួយរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការការពារ និងការលើកស្ទួយនូវសិទ្ធិមនុស្ស ហើយយើងទន្ទឹងរង់ចាំដោយក្តីសោមនស្សរីករាយចំពោះ**ការបន្តអនុស្សរណៈនៃការយោគយល់**ជាមួយរាជរដ្ឋាភិបាល។